**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ៖ ៦៦ អនក្រ បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើត និងដាក់ឱ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាព**

**ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពី គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៧៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពី ការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.**

អនុក្រឹត្យនេះមានគោលដៅបង្កើត និងដាក់អោយអនុវត្តចំណាយប្រតិបត្តិការអាទិភាពក្នុង ក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ ស្របតាម គោលការណ៍សុខដុមនីយកម្ម ការតម្រឹម និងការកែតម្រូវ។

## ជំពូកទី ២
## គោលការណ៍នៃការចំណាយប្រតិបត្តិការអាទិភាព

**មាត្រា ២.**

ចំណាយប្រតិបត្តិការអាទិភាព គឺជាចំណាយប្រតិបត្តិការសរុបសម្រាប់ផ្តល់ជូនមន្ត្រីរាជការដែលត្រូវបានជ្រើសរើសអោយ បំពេញការងារ ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ។ ចំណាយប្រតិបត្តិការអាទិភាពនឹងត្រូវបញ្ចប់នៅពេលលទ្ធផលដែលបានគ្រោងទុកត្រូវបានសម្រេច ឬ គម្រោង ឬ កម្មវិធីសហប្រតិបត្តិការអភិវឌ្ឍត្រូវបានបញ្ចប់។

**មាត្រា ៣.**

ចំណាយប្រតិបត្តិការអាទិភាព មិនមែនជាប្រាក់បៀវត្ស ឬ ជាប្រាក់ ឧបត្ថម្ភបន្ថែមលើបៀវត្សឡើយ។

**មាត្រា ៤.**

ក្នុងការអនុវត្តគម្រោងសហប្រតិបត្តិការអភិវឌ្ឍ ដៃគូអភិវឌ្ឍមិនអាចផ្តល់ជូនមន្ត្រីរាជការនូវចំណាយប្រតិបត្តិការណាមួយ ក្រៅពីចំណាយប្រតិបត្តិការអាទិភាពនេះឡើយ លើកលែងតែមានការអនុញ្ញាតជាផ្លូវការពីរាជរដ្ឋាភិបាល។

## ជំពូកទី ៣
## កម្រិតចំណាយប្រតិបត្តិការអាទិភាព

**មាត្រា ៥.**

ចំណាយប្រតិបត្តិការអាទីភាពសរុបក្នុងមួយខែ ត្រូវអនុវត្តតាមកម្រិតដូចខាងក្រោម ៖

១. កម្រិតចំណាយប្រតិបត្តិការអាទិភាពសម្រាប់ថ្នាក់ជាតិ ឬ សេវាទ្រទ្រង់ មាន ៖

- ចំណាយប្រតិបត្តិការការងារដឹកនាំកម្មវិធី
  ពី ១ ៤៧០ ០០០ រៀល ទៅ ១ ៦៨០ ០០០ រៀល
- ចំណាយប្រតិបត្តិការការងារគ្រប់គ្រងគម្រោង
  ពី ៨៤០ ០០០ រៀល ទៅ ១ ២៦០ ០០០ រៀល
- ចំណាយប្រតិបត្តិការការងារប្រតិបត្តិ
  ពី ៥០៤ ០០០ រៀល ទៅ ៧៥៦ ០០០ រៀល

២. កម្រិតចំណាយប្រតិបត្តិការអាទិភាពសម្រាប់ថ្នាក់ក្រោមជាតិឬសេវាជួរមុខ មាន ៖

- ចំណាយប្រតិបត្តិការការងារគ្រប់គ្រងគម្រោង
  ពី ៣៧៨ ០០០ រៀល ទៅ ៤៦២ ០០០ រៀល
- ចំណាយប្រតិបត្តិការការងារប្រតិបត្តិ
  ពី ២១០ ០០០ រៀល ទៅ ២៩៤ ០០០ រៀល

៣. កម្រិតចំណាយប្រតិបត្តិការអាទិភាពសម្រាប់អ្នកឯកទេសកម្រិតខ្ពស់ នឹងត្រូវកំណត់ដោយឡែកបន្ទាប់ពីមានការឯកភាពរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ។

## ជំពូកទី៤
## នីតិវិធីនៃការដាក់ឱ្យដំណើរការចំណាយប្រតិបត្តិការអាទិភាព

**មាត្រា៦.**

ការកំណត់មុខសញ្ញាមន្ត្រីរាជការសម្រាប់បំពេញការងារក្នុងក្របខ័ណ្ឌចំណាយប្រតិបត្តិការអាទិភាព ត្រូវធ្វើឡើងដោយមានតម្លាភាព ផ្អែកលើលក្ខខណ្ឌយោង លក្ខណសម្បត្តិសក្តិសមមានសមធម៌ និងមាននីតិវិធី និងបែបបទច្បាស់លាស់។

**មាត្រា៧.**

នីតិវិធីនិងបែបបទនៃការដាក់អោយដំណើរការចំណាយប្រតិបត្តិការអាទិភាព ត្រូវកំណត់ក្នុងឯកសារណែនាំស្តីពីការអនុវត្តចំណាយប្រតិបត្តិការអាទិភាព ដែលរៀបចំដោយគណៈកម្មាធិការដឹកនាំការងារដើម្បីពិនិត្យ និងដោះស្រាយបញ្ហាប្រាក់ឧបត្ថម្ភបន្ថែមក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយមានការពិភាក្សាជាមួយដៃគូអភិវឌ្ឍ។

**មាត្រា៨.**

ចំណាយប្រតិបត្តិការអាទិភាព ត្រូវចាប់អនុវត្តពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១០។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា៩.**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១០.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ